**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រ.ក/លេខ១០.០៣៥/០៧ គជប.អគ្គ.៣ស**

ភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៧

# ចំនួនតំណាងគណបក្សនយោបាយដែលចូលរួមសង្កេតការណ៍លើដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ ២០០៧

គិតចាប់ពីថ្ងៃទី ០៧ ខែ កញ្ញា ដល់ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧ មានតំណាងគណបក្សនយោបាយពេញសិទ្ធិ ចំនួន **៤.៩១៣** នាក់ និងបម្រុង ចំនួន **៤.៤០០** នាក់ ក្នុងនោះស្ត្រីមានចំនួន **៥៦៧** នាក់ បានចូលរួមសង្កេតការណ៍ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ ២០០៧ នៅទូទាំង ២៤ ខេត្ត ក្រុង ។

តំណាងគណបក្សនយោបាយទាំងនេះ មកពីគណបក្សនយោបាយចំនួន **៦** មានដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- គណបក្សប្រជាជនកម្ពុជា មានតំណាង | ចំនួន **1,487** នាក់ | បម្រុង **1,384** នាក់ | ក្នុងនោះស្ត្រី **132** នាក់ |
| ២- គណបក្សហ៊្វុនស៊ិនប៉ិច មានតំណាង | ចំនួន **1,211** នាក់ | បម្រុង **1,090** នាក់ | ក្នុងនោះស្ត្រី **186** នាក់ |
| ៣- គណបក្សសម រង្ស៊ី មានតំណាង | ចំនួន **1,392** នាក់ | បម្រុង **1,225** នាក់ | ក្នុងនោះស្ត្រី **163** នាក់ |
| ៤- គណបក្សនរោត្តម រណឫទ្ធិ មានតំណាង | ចំនួន **799** នាក់ | បម្រុង **679** នាក់ | ក្នុងនោះស្ត្រី **80** នាក់ |
| ៥- គណបក្សសិទ្ធិមនុស្ស មានតំណាង | ចំនួន **23** នាក់ | បម្រុង **22** នាក់ | |
| ៦- គណបក្សប្រជាធិបតេយ្យខ្មែរ មានតំណាង | ចំនួន **01** នាក់ | | |
| | សរុបចំនួន **4,913** នាក់ | បម្រុង **4,400** នាក់ | ស្ត្រីចំនួន **561** នាក់ |

សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៧ គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវ(នៅក្រសួងមហាផ្ទៃ)តាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិចាត់តាំងតំណាងពេញសិទ្ធិរបស់ខ្លួន មួយ (១)នាក់ និងបម្រុងមួយ (១)នាក់ ដើម្បីសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅតាមសាលាឃុំ សង្កាត់ ចាប់ពីថ្ងៃទី ០៧ ខែកញ្ញា ដល់ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៧។

គណបក្សនយោបាយ ត្រូវដាក់ពាក្យសុំចុះឈ្មោះជាតំណាងនៃគណបក្សនយោបាយ នៅក្រុមប្រឹក្សាឃុំ សង្កាត់ តាមទម្រង់បែបបទលេខ ១០០៧ ហើយពាក្យសុំនេះ ត្រូវផ្តល់ជូនដោយឥតគិតថ្លៃ ។